# សុន្ទរកថាបិទ

## សិក្ខាសាលា ស្តីពី " យុទ្ធសាស្ត្រផ្តល់ព័ត៌មាន "

## ដោយ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប

## ភ្នំពេញ សណ្ឋាគារកាំបូឌីយ៉ាណា ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩

**សូមគោរព !**

- **លោកស្រី Michelle Labeeu តំណាងសហគមន៍អឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា**
- **លោក Alexandre Castanias អ្នកជំនាញការព័ត៌មានសហគមន៍អឺរ៉ុបប្រចាំ គ.ជ.ប**
- **អស់លោក លោកស្រី នាងកញ្ញា សមាជិក សមាជិកានៃអង្គសិក្ខាសាលាជាទីរាប់អាន**

សិក្ខាសាលាដែលមានរយៈពេល ២ថ្ងៃកន្លងមកនេះ បានប្រព្រឹត្តទៅក្នុងបរិយាកាសមួយដ៏ល្អ ដោយអស់លោក លោកស្រី នាងកញ្ញា ដែលជាសមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងអស់បានចូលរួមជាគំនិត យោបល់ បទពិសោធ ប្រកបដោយការស្ថាបនា សំដៅបង្កើនការយល់ដឹងជំនាញដើម្បីរួមចំណែកតាមតួនាទីធ្វើឱ្យដំណើរការផ្តល់ព័ត៌មាន របស់គជប.កាន់តែល្អប្រសើរ មានប្រសិទ្ធភាព និងប្រកបដោយជោគជ័យ ។

អស់លោក លោកស្រី នាងកញ្ញាទាំងអស់បានស្វែងយល់ហើយថា អ្វីទៅជាយុទ្ធសាស្ត្រក្នុងការផ្តល់ព័ត៌មាន ហើយមួយទៀតអស់លោក លោកស្រី នាងកញ្ញាទាំងអស់ក៏បានយល់ដែរអំពីការផ្តល់ព័ត៌មានជាស្ថាប័ន វាខុសគ្នាពីការផ្តល់ព័ត៌មានបែបទីផ្សារ ព័ត៌មានបែបមនុស្សធម៌ និងព័ត៌មានបែបសាជីវកម្ម ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមរំឭកខ្លះៗអំពីការផ្តល់ព័ត៌មានរបស់ គជប. ។

តាមសិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន ដែលមានចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គជប.ក៏មានភារកិច្ចក្នុងការងារអប់រំសាធារណជន អប់រំអ្នកបោះឆ្នោត និងការងារព័ត៌មានដែរ ដូចនេះគ.ជ.ប គឺជាស្ថាប័នផ្តល់ព័ត៌មាន ហើយព័ត៌មានដែលផ្សាយចេញទៅមានគោលដៅច្បាស់លាស់ ។ គោលដៅទី១ គឺគណបក្សនយោបាយ ដែលចូលរួមក្នុងការបោះឆ្នោត អ្នកបោះឆ្នោត អ្នកសង្កេតការណ៍ ស្ថាប័ន និងអ្នកពាក់ព័ន្ធឯទៀត និងគោលដៅទី២ គឺប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលត្រូវផ្សព្វផ្សាយបន្ត ។ ក្រៅពីការជួបដោយផ្ទាល់ និងជាប្រចាំជាមួយគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័ត៌មាន គ.ជ.ប ក៏មានចេញប្រកាសព័ត៌មានស្តីអំពីសេចក្តីសំរេចរបស់គ.ជ.ប ព្រឹត្តិការណ៍ពាក់ព័ន្ធ ឬក៏ព័ត៌មានចាំបាច់ផ្សេងទៀត រួចបញ្ជូនព័ត៌មានទាំងនេះដោយផ្ទាល់ ឬដោយប្រយោល តាមច្រើនមធ្យោបាយដែលមាន ទៅឱ្យក្រុមគោលដៅដើម្បីអនុវត្ត ឬផ្សព្វផ្សាយបន្តតាមតួនាទី ។ នៅក្នុងពេលរៀបចំការបោះឆ្នោត ទំនាក់ទំនងដោយផ្ទាល់ជាមួយគោលដៅ ដូចជាការជួបប្រជុំជាមួយគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងស្ថាប័នពាក់ព័ន្ធ ដែលត្រូវបានធ្វើជាទៀងទាត់ គឺជាទំនាក់ទំនងមានសារសំខាន់ណាស់ ព្រោះមិនគ្រាន់តែជាការផ្តល់ព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការទទួលព័ត៌មាន ការ

ផ្លាស់ប្តូរយោបល់ ដើម្បីដោះស្រាយ ឬកែតម្រូវ ក្នុងគោលបំណងពង្រឹងកិច្ចសហការ បង្កើនប្រសិទ្ធភាពការផ្តល់ព័ត៌មាន និងការផ្សព្វផ្សាយ ។ ការជួបប្រជុំបែបនេះក៏ត្រូវបានអនុវត្តផងដែរនៅថ្នាក់រាជធានី ខេត្ត និងឃុំ សង្កាត់ ។

ការផ្តល់ព័ត៌មានមួយទៀតដែល គ.ជ.ប បានធ្វើកន្លងមក គឺការចែកប័ណ្ណព័ត៌មានជូនអ្នកបោះឆ្នោត ។ ប័ណ្ណព័ត៌មានគឺជាសន្លឹកព័ត៌មានផ្ទាល់របស់អ្នកបោះឆ្នោតម្នាក់ៗ ។ ការចែកប័ណ្ណព័ត៌មាននេះ គឺជាការបញ្ជូនព័ត៌មានដោយផ្ទាល់ពី គ.ជ.ប ទៅដល់អ្នកបោះឆ្នោតតែម្តង ។ នេះជាវិធីសាស្ត្រមួយដែល គ.ជ.ប បានបញ្ជ្រាបព័ត៌មានឱ្យដល់អ្នកបោះឆ្នោត សំខាន់អ្នកបោះឆ្នោតនៅតំបន់ដាច់ស្រយាល ។ ទោះបីការចែកប័ណ្ណព័ត៌មានត្រូវបានទទួលការរិះគន់អំពីនីតិវិធីនៃការចែកខ្លះក្តី ក៏ប្រសិទ្ធភាពនៃប័ណ្ណព័ត៌មានមានកម្រិតខ្ពស់ ហើយ គ.ជ.ប នៅតែត្រៀមបន្តការងារនេះទៀតសម្រាប់ការបោះឆ្នោតសកលនាពេលខាងមុខ ។

យើងអាចនិយាយបានថា អ្នកបោះឆ្នោតគឺជាទីផ្សារ ។ ដូច្នេះគណបក្សនយោបាយនីមួយៗ បានប្រឹងប្រែងរកវិធីគ្រប់បែបយ៉ាងដើម្បីទាញយកនូវផលប្រយោជន៍រៀងៗខ្លួន ដើម្បីបានសំលេងឆ្នោតច្រើន ។ គណបក្សនយោបាយក៏មានភារកិច្ចផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតដែរ ប៉ុន្តែពិតណាស់ថាព័ត៌មាននោះនិងលំអៀងទៅតាមផលប្រយោជន៍ ដូចនេះការផ្តល់ព័ត៌មានរបស់ស្ថាប័នបោះឆ្នោតត្រូវតែដើរនូវតួនាទីស្នូល និងមានប្រសិទ្ធភាពជាង ។

ឆ្លងតាមសិក្ខាសាលានេះ សិក្ខាកាមទាំងអស់អាចយល់បានច្រើន ជាពិសេសលើចំណេះដឹងបច្ចេកទេស ផ្នែកព័ត៌មានថ្មីត្បិតតែមន្ត្រីរបស់ គ.ជ.ប មួយចំនួនដែលមានវត្តមាននៅក្នុងសិក្ខាសាលានេះពុំបានធ្វើការជំនាញទៅលើផ្នែកជំនាញព័ត៌មាននេះក៏ដោយ ក៏សិក្ខាកាមទាំងអស់ទទួលបាននូវចំណេះដឹងថ្មីមួយទៀតដើម្បីរួមចំណែកក្នុងការងារផ្តល់ព័ត៌មានរបស់គជប. កាន់តែល្អប្រសើរ មានប្រសិទ្ធភាព និទទួលបានជោគជ័យ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហគមន៍អឺរ៉ុបដែលបានសហការនិងបើកសិក្ខាសាលានេះ ហើយពិសេសខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដល់លោក **Alexandre Castanias** អ្នកជំនាញការព័ត៌មានប្រចាំ គ.ជ.ប ដែលលោកបានខិតខំប្រឹងប្រែងធ្វើការឧទ្ទេសនាម បង្ហាញ អំពីជំនាញផ្នែកយុទ្ធសាស្ត្រផ្តល់ព័ត៌មាននេះអស់រយៈពេល ២ថ្ងៃ តែម្នាក់ឯង ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការ សម្រេចបានលទ្ធផលត្រចះត្រចង់នៃអង្គសិក្ខាសាលានេះ ។

តាមដែលខ្ញុំដឹង តាមកិច្ចព្រមព្រៀងនៃការយោគយល់គ្នារវាងសហគមអឺរ៉ុប និងគជប. ក្នុងបេសកកម្មរបស់លោក **Alexandre Castanias** នៅ គ.ជ.ប បន្ទាប់ពីសិក្ខាសាលានេះទៅ នៅពេលខាងមុខនេះនឹងមានគម្រោងធ្វើសិក្ខាសាលា ២ ឬ ៣ ជាបន្តទៀត ដែលនឹងផ្តោតទៅលើការកសាងសមត្ថភាពផ្នែកបណ្តុះបណ្តាល ( Training Capacity Building ) ការតាមដានព័ត៌មាន (Media Monitoring) និងយុទ្ធនាការផ្សព្វផ្សាយដ៏ទូលំទូលាយសម្រាប់ការអប់រំសាធារណៈជន (Mass Media Campaign for CIVIC Education Campaign ) ។

ខ្ញុំសូមស្វាគមន៍ចំពោះសិក្ខាសាលាដែលនឹងត្រូវរៀបចំឡើងជាបន្តបន្ទាប់ទៀតនោះ និងត្រៀមសហការល្អជានិច្ច ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជូនអស់លោក លោកស្រី នាងកញ្ញាទាំងអស់ដែលបានចូលរួមក្នុងឱកាសនេះ សូមប្រកបតែនឹងសេចក្តីសុខចម្រើនគ្រប់ប្រការ ។

ខ្ញុំសូមប្រកាសបិទអង្គសិក្ខាសាលា ។

**សូមអរគុណ**